**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**
សំណុំរឿងព្រហ្មទណ្ឌលេខ: ១២៥៨ អ.ក
ចុះថ្ងៃទី២០-កក្កដា-២០២៣
សាលក្រមលេខ: **៥៤** /គ
ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤

**តាមនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងខេត្តកណ្ដាល**

-បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តកណ្ដាល នាថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ វេលាម៉ោង០៩ព្រឹក ដោយមានសមាសភាពដូចតទៅ÷

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] អនុប្រធានសាលាដំបូងខេត្តកណ្ដាល

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្ដាល

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្ដាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: **១២៥៨ អ.ក** ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ÷

១- ឈ្មោះ [redacted] **ស្រីសៀន** ភេទស្រី អាយុ៤៥ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមេផ្ទះ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] សឿង (ស្លាប់) ម្ដាយឈ្មោះ [redacted] ហៀង (រស់) ប្ដីឈ្មោះ [redacted] សំអុល (រស់) មានកូនចំនួន ០៥នាក់ ជានីតិជន ទោសពីមុន÷គ្មាន។ **(ក្រៅឃុំ)**

-ជាប់ចោទពីបទ: **បរិហារកេរ្តិ៍ជាសាធារណៈ** ប្រព្រឹត្តនៅភូមិលេខ៥ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៣០៥** នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សោភ័ណ** ភេទប្រុស អាយុ៣៥ឆ្នាំ មុខរបរ ចៅសង្កាត់រង សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ លេខ៤ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

-លោកមេធាវី [redacted] ការិយាល័យមេធាវី **សិង្ហាល័យ** មានអាសយដ្ឋាន ស្ថិតនៅយូនីតG ជាន់ទី៧ អគារធីខេសែនត្រល វិថីសម្ដេចប៉ែននុត ភូមិទី១៣ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណី។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: ៣៥៩ ដប.ជរ/២៣ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជំរះផ្ទាល់លេខ: ១៤៥៦ ដកចត/២៣ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល។

***<u>អង្គហេតុមានដូចតទៅ</u>***

កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ០៣ និង ០០នាទីរសៀល ស្ថិតនៅក្នុងភូមិលេខ៥ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល មានឈ្មោះ [redacted] ស្រីសៀន បានចូលរួមក្នុងអង្គប្រជុំបក្ស ហើយពេលនោះ ឈ្មោះ [redacted] ស្រីសៀន បាននិយាយក្នុងអង្គប្រជុំថា "លោក [redacted] សោភណ បានលួងលោមកូនស្រីរបស់



Scanned with CamScanner

នាងខ្ញុំ យកទៅចាប់រំលោភនៅក្នុងព្រៃ" ដែលធ្វើប៉ះពាល់ដល់កិត្តិយសរបស់ឈ្មោះ [redacted] សោភណ ព្រោះករណីខាងលើនេះឈ្មោះ [redacted] ស្រីលា ត្រូវជាកូនស្រីរបស់ឈ្មោះ [redacted] ស្រីសៀន ក៏បានទទួលស្គាល់ថាជាការព្រមព្រៀងរួមភេទ មិនមែនជាការរំលោភសេពសន្ថវៈនោះឡើយ។

**ពេលសវនាការ**

-លោកក្រឡាបញ្ជីបានអានចម្លើយរបស់ជនជាប់ចោទ [redacted] **ស្រីសៀន** បានឆ្លើយថា: កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣ វេលាម៉ោង ០៣រសៀល ស្ថិតនៅភូមិ៥ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល ខ្លួនពិតជាបាននិយាយនៅ ក្នុងអង្គប្រជុំថា ឈ្មោះ [redacted] សោភ័ណ បានលួងលោមកូនស្រីរបស់ខ្លួន ឈ្មោះ [redacted] ស៊ីលា យកទៅរំលោភ ពិតប្រាកដមែន។ ខ្លួននិយាយបែបនេះដោយសារកូនស្រីរបស់ខ្លួនបានប្រាប់ថា ឈ្មោះ [redacted] សោភ័ណ បានលួងលោម និងចាប់រំលោភកូនស្រីខ្លួននៅក្នុងព្រៃ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សោភ័ណ** បានឆ្លើយបញ្ជាក់ថា: ឈ្មោះ [redacted] ស្រីសៀន បាននិយាយបរិហារកេរ្តិ៍ខ្លួនជាសាធារណៈ ដែលបាននិយាយនៅក្នុងអង្គប្រជុំបក្សភ្លើងទៀន។ ហើយខ្លួនបានដឹងតាមរយៈវីដេអូដែលមិត្តភក្តិរបស់ខ្លួនផ្ញើឱ្យមើល ឃើញថាឈ្មោះ [redacted] ស្រីសៀន បាននិយាយបង្ខូចកេរ្តិ៍ខ្លួនជាសាធារណៈនៅក្នុងអង្គប្រជុំរបស់បក្សភ្លើងទៀន ដោយបាននិយាយថា ខ្លួនបានចាប់កូនស្រីគាត់យកទៅរំលោភនៅក្នុងព្រៃ។ ឈ្មោះ [redacted] ស្រីសៀន បាននិយាយមិនមែនជាការពិតនោះ ដោយហេតុថាខ្លួន និងកូនស្រីរបស់គាត់បានរួមរស់ជាមួយគ្នាដូចប្តីប្រពន្ធនឹងគ្នាទៅហើយ។ ប៉ុន្តែមួយរយៈចុងក្រោយនេះ ខ្លួនឈឺ ហើយបានយកទូរស័ព្ទរបស់ខ្លួនទៅលក់ ដើម្បីយកលុយទៅសរាកព្យាបាលជំងឺនៅមន្ទីរពេទ្យ ទើបខ្លួនមិនបាននៅជាមួយកូនស្រីរបស់គាត់ ហើយគាត់គិតថាខ្លួនដោះដៃចោលកូនស្រីគាត់ ទើបគាត់និយាយបរិហារកេរ្តិ៍ខ្លួនបែបនេះ។ ឈ្មោះ [redacted] ស្រីសៀន បាននិយាយធ្វើឱ្យប៉ះពាល់ដល់កិត្តិយសរបស់ខ្លួន ដូច្នេះខ្លួន សូមទារទាមសំណងជម្ងឺចិត្តចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក។

-ក្រឡាបញ្ជីអានឯកសារនានានៅក្នុងសំណុំរឿងនេះ។

**សិទ្ធិនិយាយស្តីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល**

**-មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សោភ័ណ បានសន្និដ្ឋានថា:** ឈ្មោះ [redacted] ស្រីសៀន បាននិយាយបរិហារកេរ្តិ៍កូនក្តីរបស់ខ្លួនជាសាធារណៈ ដែលបាននិយាយនៅក្នុងអង្គប្រជុំបក្សភ្លើងទៀន។ ដោយបាននិយាយថា កូនក្តីខ្លួន បានលួងលោមកូនស្រីរបស់គាត់យកទៅរំលោភនៅក្នុងព្រៃ ទាំងដែលសម្តីរបស់កូនស្រីរបស់គាត់បានបញ្ជាក់ថា: ការរួមភេទនោះ ជាការព្រមព្រៀង និងមិនការបង្ខិតបង្ខំនោះទេ។ ហើយកូនក្តីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការនិយាយរបស់ឈ្មោះ [redacted] ស្រីសៀន នោះទេ ដែលនាំឱ្យមានការប៉ះពាល់ដល់កិត្តិយសកូនក្តីរបស់ខ្លួន។ ហើយកូនក្តីខ្លួនសូមទាមទារសំណងជម្ងឺចិត្តចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក។

**-តំណាងអយ្យការបានសន្និដ្ឋានថា:** មានភស្តុតាងគ្រប់គ្រាន់ក្នុងការដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] ស្រីសៀន ភេទស្រី អាយុ៤៥ឆ្នាំ ពីបទ: **បរិហារកេរ្តិ៍ជាសាធារណៈ** ពិតប្រាកដមែន ដូច្នេះតំណាងអយ្យការសូមរក្សាការចោទប្រកាន់ដូចក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខ: ៣៥៩ ដប.ជវ/២៣ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

**ផ្អែកតាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល**

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ស្រីសៀន**។

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សោភ័ណ**។

-ក្រោយពីបានស្តាប់ការអានឯកសារនានា។

-ក្រោយពីបានពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង។/ល



Scanned with CamScanner

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សោភ័ណ**។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់។

**សំអាងហេតុ**

**តុលាការយល់ឃើញថា**

១- កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣ ពិតជាមានករណី **បរិហារកេរ្តិ៍ជាសាធារណៈ** បង្កឡើងដោយឈ្មោះ [redacted] **ស្រីសៀន** ប្រព្រឹត្តនៅភូមិលេខ៥ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល បាននិយាយបរិហារកេរ្តិ៍ ឈ្មោះ [redacted] សោភ័ណ នៅក្នុងអង្គប្រជុំបក្ស ប្រាកដមែន។

២- ក្រោយពីបានស្ដាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ស្រីសៀន** បានឆ្លើយបញ្ជាក់ថាៈ ខ្លួនពិតជា បាននិយាយនៅក្នុងអង្គប្រជុំថា ឈ្មោះ [redacted] សោភ័ណ បានលួងលោមកូនស្រីរបស់ខ្លួន ឈ្មោះ [redacted] ស្រីលា យកទៅរំលោភ ពិតប្រាកដមែន។ ខ្លួននិយាយបែបនេះដោយសារកូនស្រីរបស់ខ្លួនបានប្រាប់ថា ឈ្មោះ [redacted] សោភ័ណ បានលួងលោម និងចាប់រំលោភកូនស្រីខ្លួននៅក្នុងព្រៃ។ តុលាការពិចារណាឃើញថាៈ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស្រីសៀន ផ្ទុយនឹងចម្លើយកូនស្រីឈ្មោះ [redacted] ស្រីលា បញ្ជាក់ថា ឈ្មោះ [redacted] សោភ័ណ និងខ្លួន បានព្រមព្រៀងគ្នារួមភេទ ដែលចម្លើយនេះឈ្មោះ [redacted] ស្រីលា បានឆ្លើយនៅក្នុងលិខិតសំណូមពរសូមគោរពចូលមកលោកអធិការដ្ឋាននគរបាលក្រុងតាខ្មៅ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ដូច្នេះការនិយាយរបស់ឈ្មោះ [redacted] ស្រីសៀន មិនមែនជាការពិតនោះទេ។

៣- ផ្អែកតាមចម្លើយរបស់ដើមបណ្ដឹងឈ្មោះ [redacted] **សោភ័ណ** និងឯកសារនានាបញ្ជាក់បានថាៈ ជនជាប់ចោទឈ្មោះ [redacted] **ស្រីសៀន** ពិតជាបាននិយាយអះអាងបំផ្លើស ទម្លាក់កំហុសដោយអសុទ្ធិចិត្តទៅលើជនរងគ្រោះឈ្មោះ [redacted] **សោភ័ណ**។

៤- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] **ស្រីសៀន** ដែលបាននិយាយបរិហារកេរ្តិ៍ជាសាធារណៈ នូវអង្គហេតុមិនពិត ហើយដែលនាំឱ្យមានទណ្ឌកម្មព្រហ្មទណ្ឌ ធ្វើឱ្យប៉ះពាល់ដល់កិត្តិយស សេចក្ដីថ្លៃថ្នូរអ្នកដទៃ គឺជាបទល្មើសព្រហ្មទណ្ឌបទៈ **បរិហារកេរ្តិ៍ជាសាធារណៈ** បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៣០៥** នៃក្រមព្រហ្មទណ្ឌ។

៥- សន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សោភ័ណៈ** កូនក្ដីរបស់ខ្លួនមិនបានប្រព្រឹត្តដូចការនិយាយរបស់ឈ្មោះ [redacted] ស្រីសៀន នោះទេ ដែលនាំឱ្យមានការប៉ះពាល់ដល់កិត្តិយសកូនក្ដីរបស់ខ្លួន។ ហើយកូនក្ដីខ្លួនសូមទាមទារសំណងជម្ងឺចិត្តចំនួន ៥០,០០០ (ប្រាំម៉ឺន) ដុល្លារអាមេរិក។ ឃើញថាការទាមទារមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតុលាការពិចារណា។

៦- តំណាងអយ្យការបានប្ដឹងសុំឱ្យតុលាការតម្កល់ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់លេខៈ ៣៥៩ ដប.ជ៧/២៣ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២៣ ទុកជាបានការដដែល និងប្ដឹងសុំឱ្យតុលាការសម្រេចផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។ តុលាការនឹងពិចារណា ចំពោះការប្ដឹងសុំនេះ។

៧- ជនជាប់ចោទឈ្មោះ [redacted] **ស្រីសៀន** ជានីតិជន មានស្មារតីគ្រប់គ្រាន់អាចទទួលខុសត្រូវនូវអំពើដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន និងពុំមានភស្ដុតាងណាមួយ ដែលបញ្ជាក់ថាជនជាប់ចោទមានបញ្ហាវិបល្លាសស្មារតីនោះទេ ដូច្នេះជនជាប់ចោទមានសមត្ថភាពទទួលខុសត្រូវខាងព្រហ្មទណ្ឌ។

៨- ក្រោយពីបានពិនិត្យ ពិចារណាលើភស្ដុតាង និងរាល់សេចក្ដីសន្និដ្ឋានរបស់ភាគី តុលាការប្រកាសថាៈ មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **ស្រីសៀន** ពីបទៈ **បរិហារកេរ្តិ៍ជាសាធារណៈ** ប្រព្រឹត្តនៅភូមិលេខ៥ ៷



Scanned with CamScanner

សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣០៥** នៃក្រមព្រហ្មទណ្ឌ។

៩- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] **ស្រីសៀន** បានធ្វើឱ្យប៉ះពាល់ដល់កិត្តិយសសេចក្តីថ្លៃថ្នូររបស់អ្នកដទៃ សន្តិសុខ របៀបរៀបរយសង្គម និងច្បាប់របស់រដ្ឋ។

១០- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សោភ័ណ** បានទារសំណងជំងឺចិត្ត ជាទឹកប្រាក់ចំនួន ៥០,០០០ (ប្រាំម៉ឺន)ដុល្លារអាមេរិក។ ឃើញថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ប៉ុន្តែការទាមទារមានចំនួនច្រើនពេក គប្បីតុលាការសម្រេចឱ្យជនជាប់ចោទ បង់តាមសភាពជាក់ស្តែង និងសមហេតុផល។

**<u>សេចក្តីសម្រេច</u>**

**១- ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ** [redacted] ស្រីសៀន ភេទស្រី អាយុ៤៥ឆ្នាំ សញ្ជាតិខ្មែរ **ពិន័យជាប្រាក់ចំនួន ៥០០,០០០ (ប្រាំរយពាន់) រៀល**។

ពីបទៈ **បរិហារកេរ្តិ៍ជាសាធារណៈ** ប្រព្រឹត្តនៅភូមិលេខ៥ សង្កាត់ស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពី ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣០៥** នៃក្រមព្រហ្មទណ្ឌ។

**២- បង្គាប់ឱ្យជនជាប់ចោទឈ្មោះ** [redacted] ស្រីសៀន សងសំណងជំងឺចិត្តចំនួន **២,០០០,០០០ (ពីរលាន) រៀល** ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សោភ័ណ**។ បណ្តឹងទាមទារលើសពីនេះច្រានចោល តាមមាត្រា **១៤** និងមាត្រា **៣៥៥** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សោភ័ណ** និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **ស្រីសៀន**។ ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**
**ហត្ថលេខា និងត្រា:** [redacted]

**ចៅក្រមជំនុំជម្រះ**
**ហត្ថលេខា និងត្រា:** [redacted]

---

**បានឃើញ**
កណ្តាល, ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤
**ចៅក្រមជំនុំជម្រះ**
[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃចន្ទ ១រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
កណ្តាល, ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤
**ក្រឡាបញ្ជីសវនាការ**
[redacted]



Scanned with CamScanner